ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៩៤

ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩

សាលដីកា

លេខ ២៥ "II"

ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០

# សាលដីកា

## តាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០

ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម ៖

១. លោកស្រី [redacted] ជាប្រធាន

២. លោក [redacted] ជាចៅក្រម

៣. លោក [redacted] ជាចៅក្រម

៤. លោក [redacted] ជាចៅក្រម

៥. លោកស្រី [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ៦៩ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សារ័ត្ន និងបណ្តឹងសាទុក្ខលេខ ៧២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សារ៉ា ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ០៩ ក្រII "រ" ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ដែលមាន ៖

**- ជនជាប់ចោទ ៖**

១-ឈ្មោះ [redacted] សារ៉ា ហៅ ក្តាម ភេទប្រុស អាយុ ៣៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរគក់ជេរម៉ូតូ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] មានកូន០១ នាក់ ធ្លាប់ជាប់ពន្ធនាគារ។ (អ្នកប្តឹងសាទុក្ខ) (ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣៨៧ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧)



Scanned with CamScanner

២-ឈ្មោះ [redacted] សារ័ត្ន ហៅ ម៉ាប់ ភេទប្រុស អាយុ ២៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិផ្សារចាស់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] ធ្លាប់ជាប់ពន្ធនាគារ។ (អ្នកប្ដឹងសាទុក្ខ)(ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣៨៩ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧)

-មានលោកស្រី [redacted] សុវ៉ែន ជាមេធាវីការពារ

- **ជាប់ចោទពីបទ** ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិសំណង់ សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាសទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ នៅចំណុចភូមិសំណង់ សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ មានអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មួយបានកើតឡើង ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] សារ៉ា ហៅ ក្លាម, ឈ្មោះ [redacted] សារ័ត្ន, ឈ្មោះ ហេង និងឈ្មោះ អេង ពិតប្រាកដមែន។

សាលាដំបូងខេត្តកំពង់ស្ពឺ បានសម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៣៨៤ "ឈ" ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ ៖

១.ផ្តន្ទាទោសលើ៖

១.១.ជនជាប់ចោទឈ្មោះ [redacted] សារ៉ា ហៅ ក្លាម ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល០៦ (ប្រាំមួយ) ឆ្នាំ។

១.២.ជនជាប់ចោទឈ្មោះ [redacted] សារ័ត្ន ហៅ ម៉ាប់ ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល០៦ (ប្រាំមួយ) ឆ្នាំ។

ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិសំណង់ សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.វត្ថុចាប់យករួមមាន៖ ទូរស័ព្ទដៃចាស់ពណ៌ស ចំនួន០១គ្រឿង សម្រេចរឹបអូសជាសម្បត្តិរដ្ឋ។

-សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទហើយប្រកាសជាសាធារណៈ នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨។

-បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។



Scanned with CamScanner

សាលក្រមនេះត្រូវបានឈ្មោះ [redacted] សារ៉ា ហៅ ក្លាម ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ៨១ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

សាលក្រមនេះត្រូវបានឈ្មោះ [redacted] សារ័ត្ន ហៅ ម៉ាប់ ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ៨២ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

សាលាឧទ្ធរណ៍បានសម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ០៩ ក្រII "វ" ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ ៖

១.ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សារ៉ា និងឈ្មោះ [redacted] សារ័ត្ន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៨៤ "ឈ" ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ទុកជាបានការ។

៣.បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់។

៤.សាលដីកានេះ ជំនុំជម្រះជាសាធារណៈ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩។

-បើកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

សាលដីកានេះត្រូវបានជនជាប់ចោទឈ្មោះ [redacted] សារ័ត្ន ប្តឹងសាទុក្ខតាមបណ្តឹងលេខ ៦៨ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

សាលដីកានេះត្រូវបានជនជាប់ចោទឈ្មោះ [redacted] សារ៉ា ប្តឹងសាទុក្ខតាមបណ្តឹងលេខ ៦៨ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានថា ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ដែលតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល គឺមានសំអាងហេតុ និងកស្តុតាងត្រឹមត្រូវតាមច្បាប់ ព្រោះថាៈ នៅមុខសមត្ថកិច្ចនគរបាល ជនជាប់ចោទឈ្មោះ [redacted] សារ៉ា បានឆ្លើយសារភាពអំពីសកម្មភាពរបស់ខ្លួន និងជនជាប់ចោទឈ្មោះ [redacted] សារ័ត្ន ច្បាស់លាស់រួចហើយ។ ម្យ៉ាងថ្នាំញៀនដែលដកហូតយកបានពីឈ្មោះ [redacted] សារ៉ា គឺជាប្រភេទថ្នាំមេតំហ្វេតាមីន ដែលមានទម្ងន់ ៣៤,៣៣ក្រាម ដែលមានកំរិតភាពសុទ្ធចំនួន ៧៩,៥១% មានបរិមាណជាតុសុទ្ធចំនួន ២៧,២៩៥ក្រាម ដូចមានក្នុងសំអាងហេតុចំណុចទី២ ទី៣ និងទី៦ នៃសាលដីកាសាលាឧទ្ធរណ៍ស្រាប់។ ការបដិសេធរបស់ជនជាប់ចោទគ្រាន់តែជាការឆ្លើយដោះសារតែប៉ុណ្ណោះ។ ហេតុដូច្នេះតំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សា

Scanned with CamScanner

ជំនុំជម្រះសម្រេច តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ០៩ ក្រអ "ក" ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល។

- ជនជាប់ចោទឈ្មោះ [redacted] សារ៉ា បានឆ្លើយថា ខ្លួនសុំឱ្យកាត់ក្តីឡើងវិញពីព្រោះខ្លួនមិនបានប្រព្រឹត្តត្រូវការចោទប្រកាន់នោះទេ។ ពីដំបូងឡើយគឺឈ្មោះ [redacted] ហៅ ម៉ាប់ បានយកមួកសុវត្ថិភាពមកផ្ញើនឹងខ្លួន ក្រោយមករយៈពេលប្រហែលជា២០នាទី ទើបបានមានសមត្ថកិច្ចចុះឆែកឆេរ បានរកឃើញសារធាតុញៀននៅក្នុងមួក។

- ជនជាប់ចោទឈ្មោះ [redacted] សារ័ត្ន បានឆ្លើយថា ខ្លួនមិនបានធ្វើអ្វីខុសទេ ដោយសារឈ្មោះ [redacted] សារ៉ា បានឆ្លើយដាក់ឈ្មោះ ហេង ប៉ុន្តែសមត្ថកិច្ចបែរជាមកចាប់ខ្លួន។

- លោកស្រីមេធាវី [redacted] សុវ៉ន បានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានសិក្សាលើសំណុំរឿង និងឆ្លងតាមការសួរដេញដោលរបស់ក្រុមប្រឹក្សាជំនុំជម្រះរួចមក យើងឃើញថា រឿងហេតុនេះពីមុនដំបូងឈ្មោះ [redacted] សារ៉ា គាត់បានទទួលបញ្ញើមួក ពីឈ្មោះ ហេង យកទៅឱ្យឈ្មោះ ថា ដោយឈ្មោះ ថា គាត់មានមុខរបបជាអ្នករាយថ្ម អ៊ីចឹងហើយមួកសុវត្ថិភាពគឺយកទៅឱ្យឈ្មោះ ថា ដើម្បីពាក់។ ក្រោយពេលដែល [redacted] សារ៉ា បានទទួលមួកពីឈ្មោះ ហេង ហ្នឹងហើយបានរយៈពេលប្រហែលជា ២០នាទី សមត្ថកិច្ចក៏បានចុះឆែកឆេរនៅផ្ទះជួល របស់ [redacted] សារ៉ា ហើយក៏ពុំបានរកឃើញអ្វីទាំងអស់នៅក្នុងនោះ គឺគ្មានភស្តុតាងដែលជាថ្នាំញៀន ឬក៏វត្ថុប្រើប្រាស់សម្រាប់ជក់ថ្នាំញៀននោះទេ។ ហើយក៏បានអញ្ជើញឈ្មោះ [redacted] សារ៉ា ទៅអធិការដ្ឋាន ដើម្បីសួរនាំពីបញ្ហាហ្នឹង ក្រោយពីការសួរនាំហើយ [redacted] សារ៉ា ក៏នៅតែឆ្លើយថាខ្លួនអត់បានជួញដូរថ្នាំញៀនអីទេ។ បន្ទាប់មកទៀត មួយថ្ងៃក្រោយមកបែរជាថាឃើញមានថ្នាំញៀននៅក្នុងមួកសុវត្ថិភាពដែលឈ្មោះ ហេង បានផ្ញើ [redacted] សារ៉ា ទុកឱ្យឈ្មោះ ថា ហ្នឹង។ ហើយចំពោះឈ្មោះ [redacted] សារ័ត្ន ដែលឈ្មោះ [redacted] សារ៉ា ឆ្លើយថាគាត់បានទទួលមួកសុវត្ថិភាពពីឈ្មោះ ហេង ហៅ ម៉ាប់ ចំណែកឯឈ្មោះ [redacted] សារ័ត្ន គឺចៃដន្យអីគឺគាត់មានរូបរាងម៉ាប់ គឺគាត់ជាជនរងគ្រោះដែលជាន់ជានឈ្មោះហៅក្រៅថា ម៉ាប់ ប៉ុន្តែយើងឃើញថា ទាំងសវនាការនៅសាលាដំបូងក៏ដូចជានៅសាលាឧទ្ធរណ៍ ក៏ដូចជានៅចំពោះមុខសមត្ថកិច្ច គឺឈ្មោះ [redacted] សារ៉ា បានបញ្ជាក់យ៉ាងច្បាស់ថា ឈ្មោះ ហេង ហៅ ម៉ាប់ គឺមិនមែនឈ្មោះ [redacted] សារ័ត្ន ហៅម៉ាប់ នេះទេ។ ហេតុដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងពីររូប ស្នើសុំប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងតំណាងមហាអយ្យការ មេត្តាពិចារណាឡើងវិញលើកំណត់ហេតុដែលជនជាប់ចោទទាំងពីរបានឆ្លើយនៅមុខសមត្ថកិច្ច និងបានឆ្លើយនៅថ្ងៃនេះ។ ហេតុដូច្នេះ ខ្លួនសូមសំណូមពរ ថាបើកមិនឃើញថាមានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកទៅលើជនជាប់ចោទ ទាំងពីររូបនេះទេ ខ្លួនស្នើសុំប្រធានក្រុមប្រឹក្សាជំនុំជម្រះ ពិចារណាទៅលើ បញ្ញត្តិមាត្រា ៣៥១ នៃក្រម ព្រហ្មទណ្ឌ និងបញ្ញត្តិមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកថាខណ្ឌទី៦ ដើម្បីឱ្យកូនក្តីខ្លួនទាំងពីររួចផុតពីបទចោទផង។

Scanned with CamScanner

## តុលាការកំពូល

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៦៨ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សារ័ត្ន និងបណ្តឹងសាទុក្ខលេខ ៧២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សារ៉ា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា៤១៧, ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេច តម្កល់សាលក្រមព្រហ្មទណ្ឌ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ទុកជាបានការ ដោយប្រកាសពិរុទ្ធភាព និងផ្តន្ទាទោសជនជាប់ចោទ [redacted] សារ័ត្ន និង [redacted] សារ៉ា ដាក់ពន្ធនាគារម្នាក់ៗ កំណត់រយៈពេល ០៦ឆ្នាំ ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននោះ ជាការត្រឹមត្រូវហើយ ព្រោះថា ជាករណីប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ដោយគ្រឿងញៀនត្រូវបានរកឃើញនៅពេលដែលនគរបាលយុត្តិធម៌ឆែកឆេរលើខ្លួន និងសម្ភារៈផ្ទាល់ខ្លួនរបស់ជនជាប់ចោទ ហើយជនជាប់ចោទក៏បានឆ្លើយសារភាពបង្ហាញច្បាស់លាស់ អំពីបទល្មើសជួញដូរគ្រឿងញៀនរបស់ខ្លួនរួចហើយដែរ។ តាមលទ្ធផលកោសល្យវិច័យ សារធាតុញៀននេះឈ្មោះ មេតំហ្វេតាមីន មានកម្រិតភាពសុទ្ធ ៧៩,៥១% ហើយតាមការគណនាលើសារធាតុញៀនទាំងអស់ ដែលរឹបអូសបានមានទម្ងន់ ៣៤,៣៣ ក្រាមនោះ ឃើញថាបរិមាណភាពសុទ្ធនៃមេតំហ្វេតាមីន ដែលត្រូវពិចារណាក្នុងការផ្តន្ទាទោសមានទម្ងន់ ២៧,២៩៥ ក្រាម ស្ថិតក្នុងបទប្បញ្ញត្តិចំណុចទី៦ មាត្រា៤០ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានកម្រិតទណ្ឌកម្មដាក់ពន្ធនាគារចន្លោះពី ៥ឆ្នាំទៅ១០ឆ្នាំ និងទោសពិន័យជាប្រាក់ពី ១០លានរៀល ទៅ ២០លានរៀល។ សាលាដំបូង និងសាលាឧទ្ធរណ៍ មិនបានសម្រេចអំពីទោសពិន័យជាប្រាក់ ឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិច្បាប់ជាធរមាននេះទេ ប៉ុន្តែដោយសារតែជាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទនោះ មិនគប្បីពិចារណាលើទោសពិន័យជាប្រាក់នេះឡើយ។

៣-យល់ឃើញថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ [redacted] សារ័ត្ន និង [redacted] សារ៉ា មិនមានមូលហេតុត្រឹមត្រូវ ស្របតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ០៩ ក្រII "វ" ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវហើយ។



Scanned with CamScanner

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១- បដិសេធបណ្តឹងសាទុក្ខលេខ ៦៨ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សាវ័ត្ថ និងបណ្តឹងសាទុក្ខលេខ ៧២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សារ៉ា។

២- តម្កល់សាលដីកាព្រហ្មទណ្ឌ លេខ ០៩ ក្រប "ក" ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ទុកជាបានការ ។

*សាលដីកានេះ បានជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ និងប្រកាសនាសនាការជាសាធារណៈនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០។*

Scanned with CamScanner